**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៣៨/០៧/២០១៣ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣

**ជម្រាបមក**

**លោក រស់ សួ**

ទីលំនៅបច្ចុប្បន្ន ភូមិ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ តំណាងឱ្យលោក **ទៀប តែចតិរម្យ**

**កម្មវត្ថុ :** សំណើសុំប្តឹងបដិសេធសេចក្តីសម្រេចលេខ ៦១៦/១៣ គ.ជ.ប ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប ។

**យោង :**
- ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥
- ពាក្យបណ្តឹងរបស់លោក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៣
- លិខិតលេខ ៦១៦/១៣ គ.ជ.ប ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកថា ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលពាក្យបណ្តឹងរបស់លោក និងបានដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ ពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣ រួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា លិខិតលេខ ៦១៦/១៣ គ.ជ.ប ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សិរុត**

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh